# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩១៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សម្រាប់សភាពាណិជ្ជកម្មខេត្តពោធិ៍សាត់ អាណត្តិទី១ លើកទី២

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្ម ខេត្តពោធិ៍សាត់

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀប ចំការបោះឆ្នោតសភាពាណិជ្ជកម្ម

-បានឃើញកំណត់ហេតុ ស្តីពីលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១១

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា១:** ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តពោធិ៍សាត់ ចំនួន ១៥រូប សម្រាប់ អាណត្តិទី១ លើកទី២ ដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឧកញ៉ា **ឌុយ គី** | ២-លោក **កែវ រិទ្ធី** | ៣-លោក **ផែង សុភ័ន្ធ** |
| ៤-លោក **នូ គីមស៊ាន** | ៥-លោក **ឡេង សាខុង** | ៦-លោក **ឡេង ហួត** |
| ៧-លោក **តែ សុខធី** | ៨-លោក **ខាត់ ថៃ** | ៩-លោក **ហៀង សុផល** |
| ១០-លោក **អ៊ឹង ជីតិច** | ១១-លោក **ខួយ ម៉េត** | ១២-លោក **អ៊ុក ម៉ូរ៉ាត់** |
| ១៣-លោក **ឡាយ សួយ** | ១៤-លោក **គួច ហ៊ាវ** | ១៥-លោក **តាវ ស៊ីថា** |

**មាត្រា២:** ទទួលស្គាល់ឧកញ៉ា **ឌុយ គី** ជាប្រធានសភាពាណិជ្ជកម្មខេត្តពោធិ៍សាត់។

**មាត្រា៣:** ទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិរបស់សភាពាណិជ្ជកម្មខេត្តពោធិ៍សាត់ ដែលមានសមាសភាព ដូចខាងក្រោម:

| | |
|---|---|
| ១-ឧកញ៉ា **ឌុយ គី** | ប្រធានសភាពាណិជ្ជកម្មខេត្តពោធិ៍សាត់ |
| ២-លោក **កែវ រិទ្ធី** | សមាជិក |
| ៣-លោក **ផែង សុភ័ន្ធ** | សមាជិក |
| ៤-លោក **នូ គីមស៊ាន** | សមាជិក |
| ៥-លោក **ឡេង សាខុង** | សមាជិក |
| ៦-លោក **ឡេង ហួត** | សមាជិក |
| ៧-លោក **តែ សុខធី** | សមាជិក |
| ៨-លោក **ខាត់ ថៃ** | សមាជិក |
| ៩-លោក **ហៀង សុផល** | សមាជិក |
| ១០-លោក **អ៊ឹង ជីតិច** | សមាជិក |
| ១១-លោក **ខួយ ម៉េត** | សមាជិក |
| ១២-លោក **អ៊ុក ម៉ូរ៉ាត់** | សមាជិក |
| ១៣-លោក **ឡាយ សួយ** | សមាជិក |
| ១៤-លោក **គួច ហ៊ាវ** | សមាជិក |
| ១៥-លោក **តាវ ស៊ីថា** | សមាជិក |

**មាត្រា៤:** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តពោធិ៍សាត់ ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងសាមីខ្លួន ដូចមានចែង

ក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
ដើម្បីសុំចុះហត្ថលេខា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-សាលារាជធានី-ខេត្ត
-សភាពាណិជ្ជកម្មកម្ពុជា
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ